
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 2.08 ការរំដោះដ៏អស្ចារ្យ ( ភាគមួយ )
## និក្ខមនំ ១: ៦-១២; ២

រឿងនេះគឺនៅគ្រាដែលប្រជារាស្រ្តជាច្រើនរបស់ព្រះ រស់នៅជាទាសកររបស់ស្តេចបរទេស ។ ព្រះរាជាតែងតាំងមេដឹកនាំឲ្យត្រួតត្រាលើពួកគេ ដែលតម្រូវឲ្យធ្វើការសាងសង់រាជវាំង និងក្រុងនានា ។ ពួកមេដឹកនាំដែលត្រួតត្រាលើពួកគេ បានបង្ខំឱ្យប្រជាជនធ្វើការទាំងថ្ងៃទាំងយប់ ។ ទោះបីជាយ៉ាងនេះក្តីប្រជាជនរបស់ព្រះ នៅតែបន្តកើនចំនួនឡើងជាលំដាប់ ។ ឃើញដូច្នេះព្រះរាជាព្រួយព្រះហឫទ័យក្រៃលែង ហើយទ្រង់ប្រទានព្រះរាជបញ្ជាឲ្យសម្លាប់កូនប្រុសទាំងអស់ដែលកើតចេញពីទាសករ។ ក្នុងអំឡុងពេលនោះមានស្រ្តីម្នាក់សម្រាលបានកូនប្រុសមួយ។ នាងបានលាក់ទារកនោះអស់រយៈពេលបីខែហើយ។ ប៉ុន្តែនៅពេលដែលនាងមិនអាចបន្តលាក់បាំងទារកនោះបានទៀត នាងក៏មានវិធីដើម្បីជួយសង្គ្រោះទារកនោះ។ នាងបានប្រាប់កូនស្រីរបស់នាង ដែលត្រូវជាបងស្រីរបស់ទារកនោះ ឱ្យទៅរកដើមបបុសដែលដុះនៅតាមដងទន្លេមកឲ្យនាង។ នាងបានយកមកធ្វើជាជាលមួយ ហើយយកជ័រមកលាបផ្នែកខាងក្នុង ដើម្បីកុំឲ្យទឹកលិចចូល។ បន្ទាប់មកនាងដាក់ទារកនោះក្នុងជាល ហើយក៏បណ្តែតតាមទឹកទន្លេទៅ។ នាងបានប្រាប់កូនស្រីរបស់នាងឱ្យតាមមើលទារកនោះ។ នៅពេលបុត្រីរបស់ស្តេចយាងទៅដងទន្លេធំ ដើម្បីស្រង់ទឹក ព្រះនាងបានទតឃើញជាលនោះ ។ ទ្រង់មានព្រះរាជបញ្ជា ឲ្យអ្នកបម្រើទៅយកជាលនោះមកឲ្យទ្រង់ ។ នៅពេលដែលព្រះនាងមើលទៅខាងក្នុងជាលនោះទ្រង់ក៏ទតឃើញទារកដ៏ស្រស់ស្អាតនោះ ។ ពេលដែលព្រះនាងទតឃើញទារកនោះ ទ្រង់ដឹងថាជាកូនរបស់ទាសករបាត់ទៅហើយ ប៉ុន្តែព្រះនាងមានចិត្តអាណិតអាសូរទារកនោះ ហើយក៏សំរេចព្រះទ័យចិញ្ចឹមទារកនោះធ្វើជាបុត្ររបស់ទ្រង់ ។ ព្រះនាងបានហៅគាត់ថា «ម៉ូសេ» ដែលមានន័យថារើសចេញពីទឹក។ បន្ទាប់មកបងស្រីរបស់ទារកនោះចេញមក ហើយគាល់ព្រះនាងថា តើទ្រង់ចង់ឲ្យនាងរកមេដោះមកមើលថែរក្សាទារកនោះឬទេ ។ មេដោះដែលនាងបានហៅមកនោះ គឺគ្មាននរណាក្រៅពីម្តាយរបស់កូននោះទេ។ លោកម៉ូសេធំឡើងនៅក្នុងរាជវាំងរបស់ស្តេច ។ ថ្ងៃមួយពេលដែលគាត់ឃើញ ទាហានរបស់ស្តេចបានធ្វើបាបប្រជារាស្រ្តរបស់គាត់ គាត់មានអារម្មណ៍សោកសៅខ្លាំងមែនទែន ។ គាត់គិតថាគាត់អាចជួយសង្គ្រោះប្រជារាស្រ្តរបស់គាត់បាន ដោយប្រើប្រាស់កម្លាំងផ្ទាល់របស់គាត់ ប៉ុន្តែគាត់បានបរាជ័យ។ ថ្ងៃមួយគាត់បានព្យាយាមជួយសង្គ្រោះបុរសម្នាក់ ពីការវាយដំរបស់ទាហាន ហើយគាត់ក៏បានជ្រុលដៃសម្លាប់ទាហាននោះទៅ ។ ដោយខ្លាចព្រះចៅអធិរាជដាក់ទោស គាត់ក៏រត់ទៅវាលខ្សាច់។ លោកម៉ូសេរស់នៅក្នុងវាលខ្សាច់អស់រយៈពេលសែសិបឆ្នាំ និងមើលថែរក្សាសត្វចិញ្ចឹម ។ អស់រយៈពេលជាច្រើនឆ្នាំមក ប្រជារាស្ត្ររបស់ព្រះបានស្រែករកទ្រង់ ឲ្យជួយសង្គ្រោះពួកគេ ពីការរងទុក្ខវេទនាទាំងនោះ ។ ពួកគេបានអំពាវនាវដល់ព្រះនាមព្រះ ដើម្បីមកជួយសង្គ្រោះពួកគេ ។ ព្រះទ្រង់បានឮសម្រែកពួកគេហើយបានរៀបចំផែនការសម្រាប់ជួយសង្គ្រោះពួកគេ ។ **ទំនុកតម្កើង ៣៤:១៧** ពេលមនុស្សសុចរិតស្រែករកព្រះអង្គ ព្រះអម្ចាស់ទ្រង់ព្រះសណ្តាប់ពាក្យគេ ហើយព្រះអង្គរំដោះគេឲ្យរួចពីទុក្ខលំបាកទាំងប៉ុន្មាន ។

## 2.08 ការរំដោះដ៏អស្ចារ្យ (ភាគមួយ) សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

### កំណត់សំគាល់:

1. តាំងពីយូរយារណាស់មកហើយ ប្រជារាស្ត្ររបស់ព្រះបានរស់នៅជាទាសកររបស់ស្តេចមួយអង្គ ។ ស្តេចបានបង្ខំពួកគេឲ្យធ្វើការច្រើនណាស់ ។ ប្រជាជននៅតែបន្តមានកូន ហើយក្រុមគ្រួសាររបស់ពួកគេ នៅតែកើន ឡើង ។ ព្រះរាជាព្រួយព្រះហឫទ័យខ្លាំងមែនទែន ទ្រង់បញ្ជាឲ្យគេសម្លាប់ទារកប្រុសៗទាំងអស់ ដែលកើតចេញពីប្រជាជនទាំងនោះ ។
2. មានស្ត្រីម្នាក់បង្កើតបានកូនប្រុសមួយ ។ នាងបានលាក់ទារកនោះពីស្តេច ។ នាងបានធ្វើជាលមួយហើយដាក់កូនរបស់នាងនៅក្នុងជាលនោះ ហើយបណ្តែតទៅក្នុងទឹក ។
3. បុត្រីរបស់ស្តេចយាងមកទន្លេ ហើយឃើញជាលនោះ ។ ព្រះនាងបានឃើញទារក! ហើយបានសម្រេចចិត្តយកទារកនោះទុកសម្រាប់ខ្លួនទ្រង់ ។ ព្រះនាងដាក់ឈ្មោះគាត់ថា " ម៉ូសេ" ។
4. ម៉ូសេធំឡើងនៅក្នុងរាជវាំងរបស់ស្តេច ។ ថ្ងៃមួយគាត់បានឃើញប្រជាជនរបស់ស្តេច ធ្វើបាបប្រជាជនរបស់គាត់យ៉ាងធ្ងន់ធ្ងរ ។ គាត់បានព្យាយាមជួយ ប៉ុន្តែគាត់ក៏បានសម្លាប់ទាហានម្នាក់ដោយចៃដន្យ ។ គាត់មានការភ័យខ្លាចណាស់ ។ គាត់ក៏បានរត់ទៅវាលរហោស្ថាន ។
5. លោកម៉ូសេរស់នៅវាលខ្សាច់អស់រយៈពេលសែសិបឆ្នាំ ។ គាត់បានថែរក្សាសត្វចិញ្ចឹម ។ ប្រជាជនដែលគាត់បានចាកចោល បានចាប់ផ្តើមអំពាវនាវដល់ព្រះ ដើម្បីឲ្យទ្រង់ជួយពួកគេចាកចេញពីស្តេច ហើយទៅនៅស្រុកផ្សេង ។ ព្រះទ្រង់បានស្តាប់ឮការអធិស្ឋានរបស់ពួកគេ ហើយក៏បានរៀបចំផែនការ ដើម្បីជួយសង្គ្រោះពួកគេ។

### សំណួរ

១) តើស្តេចបានធ្វើអ្វីខ្លះ នៅពេលដែលទ្រង់ខ្លាចក្រុមគ្រួសាររបស់ទាសករ កាន់តែរីកធំទៅៗ ?
២) តើស្ត្រីម្នាក់នោះបានធ្វើអ្វីខ្លះ ដើម្បីជួយសង្គ្រោះកូនរបស់នាង?
៣) តើបុត្រីរបស់ស្តេចបានធ្វើអ្វី នៅពេលដែលទ្រង់រកឃើញទារកនោះ?
៤) តើបុត្រីរបស់ស្តេចដាក់ឈ្មោះអ្វីឲ្យទារក?
៥) ហេតុអ្វីបានជាម៉ូសេរត់ទៅវាលខ្សាច់?
៦) តើព្រះបានឮសេចក្តីអធិស្ឋានរបស់ប្រជាជនឬទេ?

### ចម្លើយ

១) ស្តេចបានសម្រេចចិត្តសម្លាប់ទារកប្រុសៗ ដែលជាកម្មសិទ្ធិរបស់ទាសករ ។
២) ស្ត្រីនោះបានធ្វើជាលមួយ ហើយដាក់កូនរបស់នាងនៅក្នុងជាលហើយបណ្តែតវាចុះទៅក្នុងទឹកទន្លេ ។
៣) បុត្រីរបស់ស្តេចបានទុកទារកជាកូនរបស់ខ្លួន ។
៤) ទារកមានឈ្មោះថាម៉ូសេ ។
៥) ម៉ូសេបានសម្លាប់ទាហានម្នាក់ ដែលបានធ្វើបាបទាសករ ដោយចៃដន្យ ។
៦) ព្រះទ្រង់បានឮសេចក្តីអធិស្ឋានរបស់ប្រជាជន ។ ទ្រង់បានរៀបចំផែនការ ដើម្បីជួយសង្គ្រោះពួកគេ ។

Kids of Destiny®
Reaching the Next Generation



www.kidsofdestiny.org